# វិញឡុង

ស្ថាប័នរបស់បក្សភាគបក្សកុម្មុយនិស្តវៀតណាមខេត្តវិញឡុង

ឆ្នាំទី ៣៩
គ្រាំងថ្មីលេខ 18 (1930)
ថ្ងៃ សុក្រ ទី ០៥ ខែកញ្ញា ឆ្នាំ ២០២៥
១៣ កើត ខែភទ្របទ ឆ្នាំម្សាញ់
សប្តស័ក ព.ស. ២៥៦៩


**ឈានដល់មហាសន្និបាតបក្សភាគគ្រប់លំដាប់ថ្នាក់ អាណត្តិកាល ២០២៥-២០៣០**

## គណៈចង្អុលការបង្ការប្រឆាំងអំពើពុករលួយ ខ្ជះខ្ជាយអសកម្មខេត្តប្រជុំលើកទីមួយ

**សប្តាហ៍**កន្លង សមមិត្ត ង៉ូជីគៀង សមាជិកគណៈប្រតិបត្តិការមជ្ឈិមបក្ស លេខាគណៈកម្មាធិការបក្សខេត្ត ប្រធានគណៈតំណាងរាស្ត្រសភានីតិកាលទី ១៥ ខេត្តវិញឡុង ប្រធានគណៈចង្អុលការបង្ការប្រឆាំងអំពើពុករលួយ ខ្ជះខ្ជាយអសកម្មខេត្តអញ្ជើញជាអធិបតីអង្គប្រជុំលើកទីមួយដើម្បីឆ្លងបណ្តាឯកសារ វាយតម្លៃស្ថានភាព លទ្ធផលធ្វើសកម្មភាពជំហានដំបូង និងពិភាក្សាបណ្តាភារកិច្ចសំខាន់ៗនាពេលខាងមុខ។

អញ្ជើញចូលរួមអង្គប្រជុំនៅមានសមមិត្ត ហូធីហ្វាងអៀង អនុលេខាអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សខេត្ត អនុប្រធានគណៈចង្អុលការបង្ការប្រឆាំងអំពើពុករលួយ ខ្ជះខ្ជាយអសកម្មខេត្ត និងបណ្តាសមាជិកគណៈចង្អុលការ ថ្នាក់ដឹកនាំស្ថាប័នតម្រួតស៊ើបអង្កេតនគរបាលខេត្ត គណៈកម្មាធិការកិច្ចការផ្ទៃក្នុងនៃគណៈកម្មាធិការបក្សខេត្ត និងការិយាល័យគណៈកម្មាធិការបក្សខេត្ត។

ចង្អុលការអង្គប្រជុំ សមមិត្ត ង៉ូជីគៀង សមាជិកគណៈប្រតិបត្តិការមជ្ឈិមបក្ស លេខាគណៈកម្មាធិការបក្សខេត្ត ប្រធានគណៈតំណាងរាស្ត្រសភានីតិកាលទី ១៥ ខេត្តវិញឡុង ប្រធានគណៈចង្អុលការបង្ការប្រឆាំងអំពើពុករលួយ ខ្ជះខ្ជាយអសកម្មខេត្តបានសង្កត់ធ្ងន់ថា៖ អង្គប្រជុំលើកដំបូងរបស់គណៈចង្អុលការមានអត្ថន័យសំខាន់ ដើម្បីវាយតម្លៃសម្ទុះកំណើនលទ្ធផលវិនិច្ឆ័យបណ្តាករណីរឿងក្តី អំពើពុករលួយខ្ជះខ្ជាយអសកម្មតាំងពីថ្ងៃទី ១/៧/២០២៥ មកដល់ពេលនេះ។ សមមិត្តលេខាគណៈកម្មាធិការបក្សខេត្ត ង៉ូជីគៀង សំណូមពរគណៈចង្អុលការតប្បីបន្តជ្រួតជ្រាប ផ្សព្វផ្សាយទាន់ពេលបណ្តាឯកសាររបស់មជ្ឈិម របាយការណ៍ក្តាប់ខ្ជាប់ស្ថានភាពជាបន្ទាន់ ជាពិសេសបណ្តាករណីរឿងស្មុគស្មាញដែលបានសង្គមយកចិត្តទុកដាក់ដើម្បីវិនិច្ឆ័យត្រឹមត្រូវតាមនីតិប្បញ្ញត្តិ។ ទន្ទឹមនឹងនោះ សំណូមពរជំរុញមាំសម្ទុះកំណើនដោះស្រាយឯកសារដែលកកកុញ ប្រញាប់ផ្សព្វផ្សាយ និងអនុវត្តបណ្តាសេចក្តីសន្និដ្ឋានរបស់អគ្គលេខាបក្ស តូឡឹម ស្តីពីបង្ការប្រឆាំងអំពើពុករលួយ ខ្ជះខ្ជាយអសកម្ម។ ការងារត្រួតពិនិត្យឃ្លាំមើលតប្បីដំណើរការជាប្រចាំ និងជម្នះភាពអន់ខ្សោយឱ្យបានទាន់ពេល។ បណ្តាផ្នែកវិស័យអនុវត្តម៉ឺងម៉ាត់បែបបទសហប្រតិបត្តិការធ្វើបច្ចុប្បន្នកម្មព័ត៌មាន ស្នើឱ្យគ្រប់គ្រាន់បជានបទដើម្បីគណៈចង្អុលការមានមូលដ្ឋានចង្អុលការ។ បណ្តាស្ថាប័នសេនាធិការតប្បីពង្រីកតួនាទី បូកសរុបលទ្ធផលបង្ការប្រឆាំងអំពើពុករលួយ ខ្ជះខ្ជាយអសកម្មដើម្បីលើកកម្ពស់ប្រសិទ្ធភាពដឹកនាំ។ ទន្ទឹមនឹងនោះពង្រីកប្រសិទ្ធភាពទូរស័ព្ទជាបន្ទាន់ដើម្បីបង្កលក្ខណៈសម្រាប់ប្រជាជនចូលរួមថ្កោលទោសឧក្រិដ្ឋជន៕

ប្រែសម្រួល៖ **រតនា**

## ប្រទានជូន និងឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្សលើក ២ កញ្ញា ឱ្យដល់បក្ខជន ១.៥២៦ រូប



*បណ្តាបក្ខជនបានទទួលសញ្ញាសម្គាល់អាយុបក្សលើក២ កញ្ញា។ រូបថត៖* **គីមឡុង**

**អំ**ណរអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហាជោគជ័យ (១៩/៨/១៩៤៥-១៩/៨/២០២៥) និងបុណ្យឯករាជ្យជាតិប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាម (០២/៩/១៩៤៥-០២/៩/២០២៥)។ គណៈកម្មាធិការបក្សខេត្តវិញឡុងចាត់តាំងពិធីប្រទានជូន និងឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្សលើក ២ កញ្ញា ឱ្យដល់បក្ខជន ១.៥២៦ រូប។ ក្នុងនោះប្រទានជូនសញ្ញាសម្គាល់អាយុដល់បក្ខជនចំនួន ១.៥១៤ រូប និងឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្សចំនួន ១២ រូប។ ក្នុងនោះប្រទានជូនសញ្ញាសម្គាល់អាយុបក្ស ៧៥ ឆ្នាំដល់បក្ខជន ០៣ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៧០ ឆ្នាំដល់បក្ខជន ០៤ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៦៥ ឆ្នាំដល់បក្ខជន ០៧ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៦០ ឆ្នាំដល់បក្ខជន ៦៣ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៥៥ ឆ្នាំដល់បក្ខជន ៩៥ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៥០ ឆ្នាំដល់បក្ខជន ១០៨ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៤៥ ឆ្នាំដល់បក្ខជន ២២១ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៤០ ឆ្នាំដល់បក្ខជន ៥៥៨ រូប ជូនសញ្ញាសម្គាល់អាយុបក្ស ៣០ ឆ្នាំដល់បក្ខជន ៤៥៥ រូប និងឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្សដល់បក្ខជនចំនួន ១២ រូប រួមមាន៖ ឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្ស ៥០ ឆ្នាំដល់បក្ខជន ០១ រូប ឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្ស ៤៥ ឆ្នាំដល់បក្ខជន ០៥ រូប ឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្ស ៤០ ឆ្នាំដល់បក្ខជន ០៥ រូប ឧទ្ទិសជូនសញ្ញាសម្គាល់អាយុបក្ស ៣០ ឆ្នាំដល់បក្ខជន ០១ រូប។

ជូនអំណោយអមតាមសញ្ញាសម្គាល់អាយុបក្ស ៧៥ ឆ្នាំគឺ ២៣.៤០០.០០០ដុង សញ្ញាសម្គាល់អាយុបក្ស ៧០ ឆ្នាំគឺ ១៨.៧២០.០០០ដុង សញ្ញាសម្គាល់អាយុបក្ស ៦៥ ឆ្នាំគឺ ១៤.០៤០.០០០ដុង សញ្ញាសម្គាល់អាយុបក្ស ៦០ ឆ្នាំគឺ ១១.៧០០.០០០ដុង សញ្ញាសម្គាល់អាយុបក្ស ៦៥ ឆ្នាំគឺ ១៤.០៤០.០០០ដុង សញ្ញា សម្គាល់អាយុបក្ស ៥៥ ឆ្នាំគឺ ៨.១៩០.០០០ ដុង សញ្ញាសម្គាល់អាយុបក្ស ៥០ ឆ្នាំគឺ ៧. ០២០.០០០ ដុង សញ្ញាសម្គាល់អាយុបក្ស ៤៥ ឆ្នាំគឺ ៥.៨៥០.០០០ដុង សញ្ញាសម្គាល់អាយុ បក្ស ៦៥ ឆ្នាំគឺ ៤.៦៨០.០០០ដុង សញ្ញាសម្គាល់អាយុបក្ស ៣០ ឆ្នាំគឺ ៣.៥១០.០០០ដុង ចំនួនប្រាក់បានដកពីមូលនិធិប្រឡងប្រណាំងស្មើចសរសើររបស់បក្ខភាគខេត្ត៕ **រតនា**

## នាំយកគោលការណ៍ សេចក្តីសម្រេចចិត្តរបស់បក្សទៅក្នុងជីវភាព

# សង្កាត់ឡុងឌឹកបញ្ជូនសេចក្តីសម្រេចចិត្តទៅក្នុងជីវភាព

*ក្រោយពីមហាសន្និបាតតំណាងបក្ខភាគអាណត្តិកាល ២០២៥-២០៣០ គណៈកម្មាធិការបក្ស រដ្ឋអំណាចគ្រប់លំដាប់ថ្នាក់ក្នុងខេត្តរួសរាន់រៀបចំ ប្រគល់ការងារដល់សមាជិកគណៈប្រតិបត្តិការ ចាត់កម្មាភិបាលដើម្បីធ្វើលំនឹងយន្តការចាត់តាំងដឹកនាំមានប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយ និងបញ្ជូនសេចក្តីសម្រេចចិត្តរបស់បក្សទៅក្នុងជីវភាព។ វិលមកកាន់សង្កាត់ឡុងឌឹកក្នុងបណ្តាថ្ងៃបុណ្យជាតិ ២ កញ្ញា យើងខ្ញុំមានអារម្មណ៍រំភើបជាមួយនឹងបរិយាកាសប្រឡងប្រណាំងពលកម្មអធិកភាពតាមបណ្តាកំណាត់ផ្លូវសង្កាត់ផ្លូវច្រក។ ទង់ជាតិក្រហមបក់រវិចតាមវាយោនៃខែសីហា ក្បួនមនុស្សធ្វើដំណើរមកកាន់ទីស្នាក់ការអនុសង្កាត់ សង្កាត់ដើម្បីទទួលប្រាក់អំណោយរបស់នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលជូនអំណរបុណ្យឯករាជ្យប្រទេសសាធារណរដ្ឋសង្គមនិយមដ៏ស្រស់ស្រាយសប្បាយចិត្ត។*

**លោកមា** ថាច់ក្សរ នៅភូមិស្មោញរីករាយឱ្យដឹងថា៖ អនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបុណ្យឯករាជ្យប្រទេសសាធារណរដ្ឋសង្គមនិយមឆ្នាំនេះប្រជាជនបានទទួលប្រាក់អំណោយរបស់នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាល ប្រជាជនយើងសប្បាយចិត្តណាស់។ ពិតជាទឹកប្រាក់មិនជាប្រមាណ ប៉ុន្តែវាត្រដាងឡើងនូវមនោសញ្ចេតនា សីលធម៌ វប្បធម៌នៃមនុស្សជាតិ និងការយកចិត្តទុកដាក់របស់បក្សរដ្ឋជាមួយនឹងប្រជាជនទូទាំងប្រទេស។

សមមិត្ត ង្វៀងវ៉ាំងញ៉ លេខាគណៈកម្មាធិការបក្សសង្កាត់ឡុងឌឹកបានឱ្យដឹងថា៖ ក្រោយពីមហាសន្និបាតតំណាងបក្ខភាគសង្កាត់ រួមជាមួយនឹងការរៀបចំ ប្រគល់ការងារកម្មាភិបាល ធ្វើលំនឹងអង្គការចាត់តាំង និងកសាងកម្មវិធីធ្វើសកម្មភាព កសាងផែនការអនុវត្តសេចក្តីសម្រេចចិត្តមហាសន្និបាតតំណាងបក្ខភាគ អាណត្តិកាល ២០២៥-២០៣០ គណៈកម្មាធិការបក្សសង្កាត់ឡុងឌឹកបានបញ្ជាក់ភារកិច្ចច្បាស់លាស់ដើម្បីជំរុញសម្ទុះកំណើនសុក្រឹតបណ្តាភាគកម្រិតដែលបានដាក់ចេញ។ ក្រៅពីការវិនិយោគរបស់រដ្ឋ បក្ខភាគសង្កាត់ និងមូលដ្ឋានបំផុសចលនាប្រជាជនរួមកម្លាំងដើម្បីរក្សាអនាម័យតាមកំណាត់ផ្លូវ កសាងសង្កាត់អារ្យធម៌ទំនើប។

ក្នុងនោះ មានតមនាគមន៍ ធារាសាស្ត្រ និងបរិស្ថានបន្តថែទាំពង្រីកគ្រប់វិស័យវប្បធម៌-សង្គមមិនបញ្ឈប់លើកកម្ពស់ជីវភាពសម្ភារស្មារតីជូនប្រជាជន។ លើកកម្ពស់គុណភាពអប់រំ និងបណ្តុះបណ្តាល យកចិត្តទុកដាក់ពង្រីកប្រភពធនធានមនុស្សឆ្លើយតបតម្រូវការអភិវឌ្ឍន៍រួមរបស់សង្កាត់ យកចិត្តទុកដាក់ថែទាំសុខភាពជូនប្រជាជន។ យកចិត្តទុកដាក់ផ្សព្វផ្សាយអនុវត្តល្អបណ្តាគោលនយោបាយចំពោះអ្នកមានសគុណ គោលនយោបាយជនជាតិ សាសនា គោលនយោបាយសុខុមាលភាពសង្គម បណ្តុះបណ្តាលវិជ្ជាជីវៈ ដោះស្រាយការងារធ្វើនៅនឹងមូលដ្ឋាន កាត់បន្ថយភាពក្រីក្រចីរភាព ជាពិសេសគ្រួសារក្រីក្រក្នុងតំបន់ជនរួមជាតិខ្មែរ។

សមមិត្ត ង្វៀងវ៉ាំងញ៉ លេខាគណៈកម្មាធិការបក្សសង្កាត់ឡុងឌឹកបានឱ្យដឹងបន្ថែមថា៖ បច្ចុប្បន្ន បក្ខភាគប្រមូលផ្តុំកម្លាំងដឹកនាំប្រព័ន្ធនយោបាយអនុវត្តសេចក្តីសម្រេចចិត្តមហាសន្និបាត។ ក្នុងនោះ កំណត់ច្បាស់និងប្រគល់ភារកិច្ចច្បាស់លាស់ដល់បណ្តាសមមិត្តគណៈប្រតិបត្តិការបក្ខភាគ សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សទទួលបន្ទុកបណ្តាសាខាបក្សស្ថិតក្រោមឱវាទដើម្បីងាយស្រួលក្នុងការក្តាប់ស្ថានភាព ចង្អុលការបានជិតដិតជាង។ ជារៀងរាល់សប្តាហ៍គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សតែងចាត់តាំងអង្គប្រជុំប្តូរវេនដើម្បីស្តាប់ការឆ្លុះបញ្ចាំងបណ្តាបញ្ហាថ្មី ទន្ទឹមនឹងនោះ ដាក់ចេញបណ្តាភារកិច្ចសំខាន់ៗអនុវត្តនាពេលខាងមុខ។ ដើម្បីទុកឱ្យសេចក្តីសម្រេចចិត្តមហាសន្និបាតបក្ខភាគប្រញាប់ស៊ីជម្រៅទៅក្នុងជីវភាព ការងារផ្សព្វផ្សាយជួយឱ្យប្រជាជនក្តាប់ខ្ជាប់បានបណ្តាខ្លឹមសាររបស់សេចក្តីសម្រេចចិត្តតែងបានដាក់ចេញជាចម្បង។ ក្នុងនោះ គោលដៅផ្សព្វផ្សាយត្រូវបានទូលំទូលាយរលូនដើម្បីទុកឱ្យប្រជាជនចូលរួមជ្រោមជ្រែងអនុវត្តមានប្រសិទ្ធភាព។ តិតមកដល់ពេលនេះ កម្រិតវិនិយោគសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាននៅសង្កាត់ឡុងឌឹកកើនឡើងជាង ១០០ ពាន់លានដុង។ រួមជាមួយនឹងនោះ គណៈកម្មាធិការបក្សសង្កាត់ឡុងឌឹក ប្រមូលផ្តុំកម្លាំងចង្អុលការបណ្តាផ្នែក រណសិរ្សមាតុភូមិ និងបណ្តាអង្គការមហាជនសង្កាត់ប្រមូលផ្តុំកម្លាំងផ្សព្វផ្សាយអនុវត្តសេចក្តីសម្រេចចិត្ត សកម្មចលនាប្រជាជនចូលរួមអនុវត្តកម្មវិធីកសាងសង្កាត់អារ្យធម៌ទំនើប និងអនុវត្តបណ្តាទម្រង់ផលិតនាំមកលទ្ធផលសេដ្ឋកិច្ចខ្ពស់ ទម្រង់ចិញ្ចឹមជ្រូកព្រៃ ទម្រង់ចិញ្ចឹមត្រីផ្ទក់។ល។ បណ្តាទម្រង់ស្វ័យគ្រប់គ្រងអំពីសន្តិសុខសណ្តាប់ធ្នាប់ អនុវត្តការងារសុខុមាលភាពសង្គម។ល។



ទិដ្ឋភាពអំណរទិវាបុណ្យជាតិ ២/៩។



ទម្រង់ចិញ្ចឹមត្រីផ្ទក់លើស្រះបណ្តោត។

រួមចំណែកកែលម្អ និងលើកកម្ពស់ប្រភពចំណូលជូនប្រជាកសិករ។

ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់របស់ទូទាំងប្រព័ន្ធនយោបាយ។ "ក្នុងរយៈពេលជាងមួយខែកន្លង រួមជាមួយនឹងការចាត់តាំងមហាសន្និបាតតំណាងបក្ខភាគសង្កាត់ឡុងឌឹកលើកទី ១ អាណត្តិកាល ២០២៥-២០៣០ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការបក្សសង្កាត់ជានិច្ចកាលចង្អុលការដល់សមាជិកគណៈប្រតិបត្តិការបក្ខភាគ សាខាបក្សស្ថិតក្រោមឱវាទកសាងកម្មវិធីធ្វើសកម្មភាពបានលំនឹង សមស្របជាមួយនឹងសមត្ថកិច្ច តម្រិះវិជ្ជា មុខជំនាញរបស់កម្មាភិបាល បុគ្គលិកនិយោជិត។ ផ្តើមពីភាពសាមគ្គី និងការប្តេជ្ញាចិត្តនយោបាយខ្ពស់ សង្ឃឹមថាមូលដ្ឋានពង្រីកបានល្អតួនាទី ភារកិច្ចរបស់ខ្លួនទៅក្នុងការបញ្ជូនសេចក្តីសម្រេចចិត្តមហាសន្និបាតបក្ខភាគទៅក្នុងជីវភាព ដើម្បីបង្កជាថាមពលវិវឌ្ឍន៍យ៉ាងសកម្មទៅលើគ្រប់វិស័យ និងបានត្រឹមត្រូវតាមការចង្អុលការរបស់សមមិត្ត ង៉ូជីកឿង សមាជិកគណៈប្រតិបត្តិការមជ្ឈិមបក្ស លេខាគណៈកម្មាធិការបក្សខេត្ត ប្រធានគណៈប្រតិភូតំណាងរដ្ឋសភា នីតិកាលទី ១៥ ខេត្តវិញឡុង៕

អត្ថបទ-រូបថត៖ **រតនា**

# បរិយាកាសអំណរបុណ្យឯករាជ្យជាតិ

*នាឱកាសអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យឯករាជ្យ ប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ទូទាំងប្រជាជនតែងទទួលបានបរិយាកាសដ៏អធិកអធម កក់ក្តៅ សប្បាយរីករាយ។ ក្តីរីករាយនោះពីព្រោះប្រជាជន កាន់តែឃើញច្បាស់ពីភាពរីកចម្រើនរបស់ប្រទេសជាតិ ក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់បក្សកុម្មុយនិស្តវៀតណាម។*



*បងស្រី សឺនធី ក្រាញ់ (ទី ២ ខាងស្តាំ) មកទទួលអំណោយក្នុងឱកាសអំណរបុណ្យជាតិ។*

**ខិត**ដល់ថ្ងៃប្រព្រឹត្តឡើងពិធីអនុស្សាវរីយ៍ តាមដងផ្លូវគ្រប់ទីកន្លែង ឃើញមានការចងទង់ជាតិ ទង់បក្ស បង្កជាទិដ្ឋភាពក្រហមប្រាលរន្ទាល។

ឆ្នាំនេះ ត្រៀមអំណរអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា ប្រជាជនក៏ទទួលបានដំណឹងរីករាយមួយនោះគឺនៅថ្ងៃទី ២៨/៨/២០២៥ ឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលប្រទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ហូឌឹកភើក បានមានសារទូរលេខបន្ទាន់លេខ ១៤៩/CĐ-TTg "ស្តីពីការជូនអំណោយដល់ប្រជាជននាឱកាសអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា"។ សារទូរលេខបានចែងថា៖ "ក្នុងបរិយាកាសទូទាំងប្រទេសអំណរអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា ប្រកបដោយភាពសប្បាយរីករាយ អធិកអធម ដើម្បីបន្តការយកចិត្តទុកដាក់យ៉ាងជ្រាលជ្រៅរបស់បក្ស និងរដ្ឋចំពោះទូទាំងប្រជាជន ផ្សព្វផ្សាយយោបល់ចង្អុលការរបស់អគ្គលេខាបក្សតូឡឹម គណៈកម្មាធិការបក្សនៃរដ្ឋាភិបាលបានជម្រាបជូនការិយាល័យនយោបាយស្តីពីការចាត់តាំងជូនអំណោយដល់ប្រជាជននាឱកាសអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា។ នៅក្នុង

*(អានតទៅទំព័រទី ៧)*

# បង្កើនការគ្រប់គ្រងទីផ្សារមុខទំនិញនាំទ្រុងចូ

**តាម**សាខានាយកដ្ឋានគ្រប់គ្រងទីផ្សារបណ្តាក្រុមគ្រប់គ្រងទីផ្សារកំពុងដំណើរការត្រួតពិនិត្យ ឃ្លាំមើលហ្មត់ចត់សកម្មភាពផលិតនិងធ្វើអាជីវកម្មនាំទ្រុងចូ គួបផ្សំនឹងការផ្សាព្វផ្សាយច្បាប់ដល់បណ្តាអង្គការចាត់តាំង បុគ្គលសំដៅរាំងស្កាត់មុខទំនិញនាំចូល និង មុខទំនិញគ្មានគុណភាព មិនច្បាស់ប្រភព ដើម្បីធានាសុវត្ថិភាពអាហារ។

សាខានាយកដ្ឋានគ្រប់គ្រងទីផ្សារពិនិត្យកត់សម្គាល់ អាស្រ័យទីផ្សារនំទ្រុងចូឆ្នាំនេះ ឆាប់ដាក់លក់ជាងរាល់ឆ្នាំ នៅតាមបណ្តាដងផ្លូវធំៗក្នុងខេត្តឃើញមានល្បែងមុខទំនិញ ដែលធ្លាប់ឃើញស្លាកសញ្ញាលក់។ ក្រៅពីកន្លែងលក់ផ្ទាល់ អាជីវកម្មជាច្រើននៅទាំងជំរុញមាំការលក់នំតាមប្រព័ន្ធអនឡាញ រួមទាំងបណ្តាកម្មវិធីលក់តាមទីផ្សារទំនើប និងឌីប៉ូដើម្បីជំរុញទីផ្សារទៀតផង។

ទន្ទឹមនឹងផលិតផលរបស់បណ្តាពាណិជ្ជសញ្ញាមានប្រិយភាព ទីផ្សារក៏បានកត់សម្គាល់នំជាច្រើនប្រភេទដែលបាននាំចូល នំធ្វើដោយហត្ថកម្មដោយមានគំរូសម្បូរបែប បង្កប់នូវគុណភាព និងសុវត្ថិភាពអាហារ។ ដើម្បីប្រកាសព្រមានដល់អ្នកប្រើប្រាស់គប្បីជ្រើសរើសមុខទំនិញនៅមូលដ្ឋានដែលមានពាណិជ្ជសញ្ញាច្បាស់លាស់បានចុះឈ្មោះ មានប្រភពច្បាស់លាស់ ជាពិសេសយកចិត្តទុកដាក់ពេលដាក់ពាក្យទិញនំតាមប្រព័ន្ធអនឡាញត្រូវសំណូមពរឲ្យផ្តល់ព័ត៌មានអាសយដ្ឋានដើម្បី ជៀសវាងមុខទំនិញក្លែងក្លាយ គ្មានគុណភាព។

ប្រែសម្រួល៖ **ថាច់ហៀង**

# សន្និបាតគំរូជឿនលឿនឃុំថ្កូវលើកទី ១ ដំណាក់កាល ២០២៥-២០៣០

*សប្តាហ៍កន្លង គណៈកម្មាធិការប្រជាជនឃុំថ្កូវ សហការជាមួយគណៈកម្មាធិការរណសិរ្សមាតុភូមិវៀតណាមឃុំចាត់តាំង សន្និបាតគំរូជឿនលឿនឃុំថ្កូវលើកទី១ ដំណាក់កាល២០២៥-២០២៣០។*




*ពិធីជូនលិខិតសរសើរដល់សមូហភាព និងបុគ្គលដែលមានស្នាដៃឆ្នើម។ រូបថត៖* **គីមតាយ**

**តាម**ការវាយតម្លៃ ក្នុងរយៈកាល ០៥ ឆ្នាំកន្លង បណ្តាចលនាប្រឡងប្រណាំងស្នេហាជាតិ នៅលើភូមិសាស្ត្រឃុំបានផ្សព្វផ្សាយទូលំទូលាយ ទាក់ទាញកម្មាភិបាល បក្ខជន និងប្រជាជនច្រើននាក់ចូលរួម។ មានបណ្តាទម្រង់មានប្រសិទ្ធភាព និងរបៀបធ្វើប្រកបដោយគំនិតច្នៃប្រតិដ្ឋជាច្រើនលេចឡើង បង្កភាពសាយភាយយ៉ាងខ្លាំងក្នុងសហគមន៍ ជាពិសេសតឹកសាងសម្រេចលក្ខហ៊ានឃុំជនបទថ្មី និងអារ្យធម៌ទីក្រុង ។

ក្នុងដំណាក់កាល ២០២១-២០២៥ ឃុំថ្កូវប្រមូលប្រភពកម្លាំងវិនិយោគកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច-វប្បធម៌-សង្គម និងជួសជុលសំណង់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ធារាសាស្ត្រ អប់រំ ចំនួន ១០៧ សំណង់ ជាមួយថវិកាសរុបរួមជាង ២.០០៥ ពាន់លានដុង។

ឃុំ ចាត់តាំងសាងសង់រួចប្រគល់ជូនផ្ទះ ៥៨៤ ខ្នងដល់គ្រួសារក្រីក្រ គ្រួសារជិតក្រ និងគ្រួសារមានស្ថានភាពលំបាក។ ផ្តើមពីនោះ រួមចំណែកបំបាត់គ្រួសារក្រីក្រ ២៥១ គ្រួសារ។ បច្ចុប្បន្ន ឃុំនៅមានគ្រួសារក្រីក្រ ១០២ គ្រួសារ (ស្មើអត្រា ១,៤%) មានគ្រួសារជិតក្រីក្រ ៣២៥ គ្រួសារ (ស្មើអត្រា ៤,៤%)។ ចលនាបំបាត់ផ្ទះបណ្តោះអាសន្ន និងផ្ទះទ្រុឌទ្រោម តែងបានយកចិត្តទុកដាក់អនុវត្ត ហើយសម្រេចបានលទ្ធផលជាក់ស្តែង។

ក្នុងដំណាក់កាល ២០២១-២០២៥ ឃុំបានផ្សព្វផ្សាយអនុវត្ត សាងសង់ផ្ទះឧបការគុណចំនួន ៤២១ ខ្នងជូនដល់កូនរបស់យុទ្ធជនពលី គ្រួសារក្រីក្រនិងគ្រួសារជិតក្រ ជាមួយថវិកាសរុបជិត ១៣ ពាន់លានដុង។

គណៈកម្មាធិការរណសិរ្សមាតុភូមិវៀតណាម សមាគមអតីតយុទ្ធជន សមាគមនារី សមាគមកសិករ និងអង្គការសម្ព័ន្ធយុវជនឃុំ បានអនុវត្តល្អចលនាប្រឡងប្រណាំងស្នេហាជាតិ បណ្តាចលនាព្រមទាំង សហការជាមួយសប្បុរសជនឧបត្ថម្ភសាងសង់ផ្ទះមហាសាមគ្គីចំនួន ៩៨ ខ្នង កសាងស្ពាន ជនបទចំនួន ០៩ និងជូនអំណោយដល់គ្រួសារក្រីក្រ គ្រួសារជិតក្រ គ្រួសារមានស្ថានភាពនិងសិស្ស។ល។

ក្នុងឱកាសនេះ មានសមូហភាព ០៥ កន្លែងនិងបុគ្គល ១៣ នាក់បានឃុំជូនលិខិតសរសើរ ដោយមានស្នាដៃឆ្នើមក្នុងដំណាក់កាល ២០២១ -២០២៥៕

**គីមតាយ-សុខា**

# សមាគមសហព័ន្ធនារីខេត្ត អុជធូបគោរពវិញ្ញាណក្ខន្ធលោកប្រធានហូជីមិញ



*ពិធីចាត់តាំងផ្តោះប្តូរតាំងពិព័រណ៍នំប្រពៃណី ថាសផ្លែឈើ សម្តែងសិល្បៈ ទាក់ទាញសមាជិកា និងមហាជនចូលរួមយ៉ាងកុះករ។*

**កាល**ពីព្រឹកថ្ងៃទី ២៩ ខែសីហា នៅតំបន់កេរដំណែលប្រវត្តិសាស្ត្របូជនីយដ្ឋាន ហូជីមិញ (សង្កាត់ឡុងឌឹក) សមាគមសហព័ន្ធន៍នារីខេត្ត បានចាត់តាំងពិធីអុជធូបជូនលោកប្រធានហូជីមិញ ក្នុងឱកាសអនុស្សាវរីយ៍គម្រប់ ៨០ ឆ្នាំទិវាបដិវត្តន៍ខែសីហា ទិវាបុណ្យជាតិថ្ងៃទី ២ ខែកញ្ញា និងខួបលើកទី ៥៦ នៃមរណភាពរបស់លោក។

នៅទីនេះ តំណាងបានធ្វើកិច្ចថ្វាយកម្រងផ្កា អុជធូបរំលឹកវិញ្ញាណក្ខន្ធ គោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកប្រធានហូជីមិញ។ ទន្ទឹមនឹងនោះ បានរំលឹកឡើងវិញនូវប្រវេណីដ៏អង់អាច្នហាន របស់ជនជាតិ។

ថ្លែងសុន្ទរកថានៅពិធីនេះ សមមិត្ត ង្វៀងធីគីមថ្វ -សមាជិកាគណៈប្រតិបត្តិការនៃគណៈកម្មាធិការបក្សខេត្ត ប្រធានសមាគមសហព័ន្ធន៍នារីខេត្តបានបញ្ជាក់ថា៖ អនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា ថ្ងៃទី ២ ខែកញ្ញា និងខួបលើកទី ៥៦ នៃការលាចាកលោករបស់អ៊ំហូ ជាឱកាសសម្រាប់កម្មាភិបាល សមាជិកា និងអង្គការចាត់តាំងសមាគមនីមួយៗរមិលមើលខ្លួនឯង អនុវត្តមានប្រសិទ្ធភាពប្រធានបទឆ្នាំ ២០២៥ អាស្រ័យមជ្ឈិមសមាគមនារីវៀតណាមបំផុសចលនា "ពង្រីកតួនាទីរបស់នារីចូលរួមកសាងបក្ស និងប្រព័ន្ធនយោបាយស្អាតស្អំ រឹងមាំ ត្រៀមចូលកាន់យុគសម័យថ្មី យុគសម័យនៃការរីកចម្រើនរបស់ប្រទេសជាតិ" ខិតខំកសាងអង្គការចាត់តាំងសមាគមសហព័ន្ធន៍នារីកាន់តែរឹងមាំ។ បន្តរក្សា អភិវឌ្ឍន៍ និងពង្រីកបានទូលំទូលាយទម្រង់រៀនសូត្រ និងធ្វើតាមសតិអារម្មណ៍ សីលធម៌ ឥរិយាបថហូជីមិញ កសាងបណ្តាទម្រង់ជាក់ស្តែងដូចជា៖ ក្រុមឡអង្ករមេត្តាធម៌ ក្រុមចិញ្ចឹមជ្រូកដី ក្រុមសប្បុរសធម៌ ក្រុមមនុស្សធម៌ ទូដាក់សម្ភារសប្បុរសធម៌ គ្រាប់អង្ករមេត្តាធម៌ ជំរុញមាំចលនាប្រឡងប្រណាំង "ប៉ិនប្រសប់កិច្ចការប្រជាចលនា" ជាដើម។

ក្នុងឱកាសនេះដែរ សមាគមសម្ព័ន្ធន៍នារីខេត្ត ចលនាសមាគមសង្គ្រោះគ្នាទៅវិញទៅមកបេនព្រែទីស្នាក់ការនៅទីក្រុងហូជីមិញជូនអំណោយដល់គ្រួសារគោលនយោបាយចំនួន ១២ ចំណែក (ក្នុងមួយចំណែក ៨០០.០០០ ដុង)។ ចាត់តាំងផ្តោះប្តូរតាំងពិព័រណ៍នំប្រពៃណី ថាសផ្លែឈើ សម្តែងសិល្បៈទាក់ទាញសមាជិកា បងប្អូននារី និងមហាជនចូលរួមយ៉ាងកុះករ៕ ប្រែសម្រួល៖ **សុជា**

# មន្ទីរស្ថាបនាខេត្តវិញឡុង ធ្វើការជាមួយបណ្តាឃុំអំពីការងារគ្រប់គ្រងសាងសង់

**ដើម្បី**ជួយ ដោះស្រាយការលំបាកជាប់ជំពាក់បានទាន់ពេលជូនដល់បណ្តាឃុំក្នុងវិស័យសាងសង់កាលពីថ្ងៃទី ២៩ ខែសីហា មន្ទីរស្ថាបនាខេត្តវិញឡុង មានឱកាសធ្វើជាមួយបណ្តាឃុំថ្កូវ តឹបស៊ើង លីវង៉ឺបរាញ់ ឡុងហ៊ីប ហាមយ៉ាង ដាយអាង ដូងចូវ ដើម្បីស្តាប់គណៈកម្មាធិការប្រជាជនបណ្តាឃុំរាយការណ៍ស្ថានភាពគ្រប់គ្រងអំពីវិស័យសាងសង់ និងបណ្តាការលំបាក ជាប់ជំពាក់សំណើ។

បណ្តាឃុំបានឱ្យដឹងថា៖ បច្ចុប្បន្ន ការងារគ្រប់គ្រងសាងសង់ជួបការលំបាកយ៉ាងច្រើន ជាពិសេសមិនទាន់មានអ្នកបានបណ្តុះបណ្តាលជំនាញក្នុងវិស័យនេះ។ ទន្ទឹមនឹងនោះ ក៏លាតត្រដាងពីការលំបាកមួយចំនួនដូចជា ការងារឡើងគ្រោងផែនការឃុំថ្មីមិនទាន់បានអនុវត្ត ការងារផ្តល់លិខិតសាងសង់ ការងារគ្រប់គ្រងនៅចំណតរថយន្តថ្កូវ ការងារសហការ ផ្តល់ជូនព័ត៌មានចំពោះបណ្តាសំណង់ស្ថិតក្រោមឱវាទខេត្តគ្រប់គ្រងលើភូមិសាស្ត្រឃុំ។ ក្រៅពីនោះ បណ្តាឃុំស្នើឆាប់ជួសជុល បង្កើនកម្រិតដងផ្លូវជាតិលេខ ៥៣ លេខ ៥៤ បង្កើនកម្រិតផ្លូវខេត្តលេខ ៩១២ កំណាតឆ្លងកាត់ឃុំហាមយ៉ាង។ គប្បីមានការណែនាំច្បាស់លាស់ក្នុងការងារគ្រប់គ្រងកំពង់ផែក្នុងខេត្ត ពីព្រោះបច្ចុប្បន្ន គណៈកម្មាធិការប្រជាជនឃុំជាអង្គភាពផ្តល់លិខិតអនុញ្ញាតផង ហើយក៏ជាអង្គភាពគ្រប់គ្រងផង។ ដើម្បីអនុវត្តល្អការងារគ្រប់គ្រងលើវិស័យសាងសង់នៅពេលខាងមុខ បណ្តាឃុំស្នើដល់ខេត្តមានដំណោះស្រាយឧបត្ថម្ភ ណែនាំឱ្យបានទាន់ពេល ផ្ទេរបញ្ជូនកម្មាភិបាលជំនាញពីខេត្តចុះមកភូមិសាស្ត្រឧបត្ថម្ភផ្ទាល់ដើម្បីរើបម្រាសការលំបាកក្នុងការគ្រប់គ្រង និងផ្តល់ការអនុញ្ញត ផ្តល់ជម្រើសបេក្ខភាពដែលបានបណ្តុះបណ្តាលផ្នែកជំនាញចូលធ្វើការ។

ថ្លែងសុន្ទរកថាសន្និដ្ឋានឱកាសធ្វើការ សមមិត្ត ញ៉ាងវ៉ាំងយ៉ា នាយករងមន្ទីរស្ថាបនាខេត្តវិញឡុង សំណូមពរ បណ្តាសមាជិកក្នុងក្រុមបូកសរុបយោបល់ សំណើ មានដំណោះស្រាយឧបត្ថម្ភទាន់ពេល ដើម្បីបណ្តាឃុំអនុវត្តល្អការងារគ្រប់គ្រងនៅពេលខាងមុខ។ ក្រៅពីនោះ សមមិត្ត ញ៉ាងវ៉ាំងយ៉ា ក៏សំណូមបណ្តាឃុំសហការគ្រប់គ្រងល្អបណ្តាកំណាតសុវត្ថិភាពចរាចរណ៍ផ្លូវគោក បំផុតគឺជំរុញមាំការងារផ្សព្វផ្សាយ បង្កើនស្មារតីយល់ដឹងក្នុងប្រជាជនគ្រប់គ្រងឱ្យបានល្អការងារសាងសង់៕

**គីមតាយ-សម្បត្តិ**

# យុវតីខ្មែរម្នាក់រូបជក់ចិត្តនឹងភ្លេងប្រពៃណី

*ប្អូនថាច់ធីយ៉េវ (នៅភូមិប្អុយដើមស្វាយ ឃុំចូវថាញ់) ចូលចិត្តស្តាប់ភ្លេងប្រពៃណីខ្មែរតាំងពីវ័យកុមារមកម្ល៉េះ។ លុះធំដឹងក្តី យ៉េវក៏ជ្រើសរៀនជំនាញផ្នែកប្រគំឧបករណ៍ភ្លេងប្រពៃណី ដោយមានបំណងចូលរួមផ្សព្វផ្សាយ អភិរក្សអត្តសញ្ញាណវប្បធម៌ប្រពៃណីជាតិនាសម័យឧស្សាហូបនីយកម្ម។*



ប្អូនថាច់ធីយ៉េវ សម្តែងសិល្បៈចម្រៀងចាប៉ីដងវែង។



ប្អូនថាច់ធីយ៉េវ ប្រគំឧបករណ៍ភ្លេងតាខេ។

**មុខ**ជំនាញផ្នែកប្រគំឧបករណ៍ភ្លេងប្រពៃណីមិនសូវមានអ្នករៀន ជាពិសេសចំពោះស្ត្រីភេទ។ ប៉ុន្តែចំពោះយ៉េវវិញជក់ចិត្តនឹងមុខជំនាញនេះណាស់ តាំងពីរៀននៅសកលវិទ្យាល័យត្រាវិញ យ៉េវតែងព្យាយាមស្រាវជ្រាវរៀនសូត្រពីប្រភពបទភ្លេង រៀនប្រគំភ្លេងប្រពៃណី ដោយក្តីស្រឡាញ់ពេញចិត្ត។ លុះដល់ជិតបញ្ចប់ការសិក្សា យ៉េវក៏ជ្រើសប្រធានបទស្វែងយល់អំពីការប្រគំភ្លេងប្រពៃណីនៅកម្មវិធីបុណ្យអកអំបុក ដើម្បីសរសេរនិក្ខេបបទ។ យ៉េវយកចិត្តទុកដាក់ស្វែងយល់អំពីឧបករណ៍ភ្លេង ២ ប្រភេទដែលមាននិន្នាការបាត់បង់ទៅនោះគឺ ឧបករណ៍តាខេ និងចាប៉ីដងវែង។ និក្ខេបបទរបស់យ៉េវ មិនត្រឹមតែអត្ថាធិប្បាយអំពីទ្រឹស្តីភ្លេងប៉ុណ្ណោះទេ នៅទាំងបញ្ជាក់អំពីខ្លឹមសារក៏ដូចជាតួនាទីនៃបទភ្លេងដែលត្រូវប្រគំនៅកម្មវិធីនីមួយៗក្នុងជីវភាពស្មារតីនៃសហគមន៍ជនរួមជាតិខ្មែរ។ ចំពោះយ៉េវ បទភ្លេងដែលប្រគំនៅកម្មវិធីនីមួយៗមានអត្ថន័យខុសគ្នា មិនត្រឹមតែផ្សារភ្ជាប់ជាមួយសហគមន៍ជនជាតិខ្មែរពីយូរលង់មកប៉ុណ្ណោះទេ នៅទាំងជាមោទនភាពរបស់ជនជាតិខ្មែរទៀតផង។

### សាយភាពភ្លេងប្រពៃណីនៅទីក្រុង

បន្ទាប់ពីបញ្ចប់ការសិក្សា យ៉េវ ទៅធ្វើការនៅទីក្រុងហូជីមិញ ដោយស្វែងរកប្រាក់សម្រាប់កសាងជីវភាពផង រកការងារធ្វើសមស្របនឹងមុខជំនាញផង។ បច្ចុប្បន្ន យ៉េវធ្វើការផ្នែកខាងហេរញ្ញិកានៅភោជនីយដ្ឋានមួយនៅទីក្រុងហូជីមិញ។ នៅពេលទំនេរ បណ្តាអង្គភាពសណ្ឋាគារ ភោជនីយដ្ឋានជាដើមអញ្ជើញយ៉េវចូលរួមប្រគំឧបករណ៍ភ្លេងប្រពៃណី ច្រៀងចម្រៀងចាប៉ីជាដើម ពេលដែលមានព្រឹត្តិការណ៍ផ្សេងៗនៅទីក្រុងហូជីមិញ ក៏ដូចជានៅខេត្តនានា។ ជាពិសេស យ៉េវបានមជ្ឈមណ្ឌលវប្បធម៌ខេត្តវិញឡុង អញ្ជើញចូលរួមជាសហការីប្រគំតន្ត្រីប្រពៃណី។ ចំពោះយ៉េវទាំងនោះមិនត្រឹមតែជាការងារប៉ុណ្ណោះទេ នៅទាំងជាឱកាសដ៏ល្អសម្រាប់រំលឹកបទភ្លេង ប្រគំភ្លេងប្រពៃណីដែលខ្លួនពេញចិត្ត។

ប្អូនយ៉េវសំណេះសំណាល៖ ទោះបីជួបការលំបាកច្រើនក៏ដោយ ប្អូនមិនបោះបង់ឆន្ទៈ ក៏ដូចជាបំណងប្រាថ្នារបស់ខ្លួនឡើយ។ ប្អូនសង្ឃឹមថាថ្ងៃណាមួយនឹងឈរជើងលើឆាកក្រុមសិល្បៈណាមួយដើម្បីប្រគំភ្លេងប្រពៃណី ឬបានជាគ្រូបង្រៀនភ្លេងដើម្បីចូលរួមផ្សព្វផ្សាយភ្លេងប្រពៃណីជូនដល់យុវជន យុវកុមារ។ ចំពោះប្អូនយល់ឃើញថា ការអភិរក្សភ្លេងប្រពៃណីខ្មែរមិនត្រឹមតែជាភារកិច្ចប៉ុណ្ណោះទេ នៅទាំងជាមោទនភាព និងសុភមង្គលរបស់ប្អូនទៀតផង។

បណ្ឌិតស៊ើងការថាំង អនុប្រធានផ្នែកភាសា-វប្បធម៌-សិល្បៈខ្មែរណាមបូ មហាវិទ្យាល័យភាសា-វប្បធម៌-សិល្បៈខ្មែរណាមបូ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យត្រាវិញ ជាគ្រូបង្រៀនផ្ទាល់ផងជាអ្នកពិនិត្យវាយតម្លៃនិក្ខេបបទរបស់យ៉េវផង បានបញ្ជាក់ថា៖ ប្អូនថាច់ធីយ៉េវ ជាយុវតីឆ្លាសវៃមានឆន្ទៈមោះមុត តស៊ូរៀនមុខជំនាញដែលពិបាករៀនលុះត្រាសម្រេចជោគជ័យ។ ប្អូនជានិស្សិតនារីម្នាក់គត់របស់វគ្គសិក្សាប្រគំភ្លេងប្រពៃណីឆ្នាំ ២០២០-២០២៤។ ដោយទឹកចិត្តស្រឡាញ់សិល្បៈប្រពៃណីខ្មែរ យ៉េវបានបន្សល់ទុកកម្រងអនុស្សាវរីយ៍ ដ៏ល្អក្នុងសន្តានចិត្តលោកគ្រូ អ្នកគ្រូ និងមិត្តរួមថ្នាក់។

យោបល់នេះ មិនត្រឹមតែបញ្ជាក់ពីស្មារតីពុះពាររបស់ប្អូនយ៉េវប៉ុណ្ណោះទេ នៅទាំងបញ្ជាក់ពីឆន្ទៈស្មារតីពុះពាររៀនប្រគំភ្លេងប្រពៃណីរបស់យុវតីថាច់ធីយ៉េវទៀងផង។ ទឹកចិត្តស្រឡាញ់សិល្បៈប្រពៃណីខ្មែរ ដែលកម្រមាននារីណាចូលចិត្តរៀន ប៉ុន្តែយ៉េវព្យាយាមរៀនលុះត្រាសម្រេចជោគជ័យ ពិតជាសក្តិសមជាគំរូល្អសម្រាប់យុវវ័យយកតម្រាប់តាម។ ប្អូនថាច់ធីយ៉េវមិនត្រឹមតែរៀនប្រគំឧបករណ៍ភ្លេងប្រពៃណីជាច្រើនប្រភេទបានស្ទាត់ជំនាញប៉ុណ្ណោះទេនៅទាំងមានទេពកោសល្យជាច្រើនទៀត គឺសំឡេងពីរោះរណ្តំ ច្រៀងបទចម្រៀងអាយ៉ៃ បទប្រជាប្រិយខ្មែរ និងរាំប្រពៃណីទៀតផង៕

អត្ថបទ-រូបថត៖ **សុខា**

# ជីវភាពធូរធា អាស្រ័យដាំក្រូចថ្លុងសម្បកខៀវចម្រុះនឹងបូង

*ដោយមានស្មារតីឆ្លងកាត់ការលំបាក ហ៊ានគិតហ៊ានធ្វើ ទើបកសិករ ឡឹមរ៉ាំងណាំ (ជនជាតិខ្មែរ) នៅភូមិចុងទ័ព ឃុំសុងឡុក បានបង្វែរផ្ទៃដីផលិតស្រូវមិនសូវមានផល ១២ កុង ឡើងចម្ការឈើហូបផ្លែ ក្នុងមួយឆ្នាំទទួលបានប្រាក់ចំណូលរាប់រយលានដុង។*

**មុន**នោះ គ្រួសាររបស់លោកមាណាំផលិតស្រូវ ១២ កុង។ ដោយសារដីមិនសូវមានជីជាតិ ទិន្នផលទាប មូលហេតុឥទ្ធិពលពីអាកាសធាតុប្រែប្រួល បណ្តាលឲ្យប្រសិទ្ធភាពសេដ្ឋកិច្ចមិនបានខ្ពស់។ នៅឆ្នាំ ២០១៥ បន្ទាប់ពីទទួលបានការផ្សព្វផ្សាយអំពីគោលការណ៍ផ្លាស់ប្តូររចនាសម្ព័ន្ធដាំដុះ និងចិញ្ចឹមសត្វ និងបានចូលរួមវគ្គហ្វឹកហាត់ បច្ចេកទេស លោកមាបានសម្រេចចិត្តបង្វែរមកដាំក្រូចថ្លុងសម្បកខៀវចម្រុះជាមួយដូង។

ដើម្បីវិនិយោគលើទម្រង់ថ្មី លោកមាណាំ បុលប្រាក់ទុន ពីធនាគារគោលនយោបាយសង្គមបាន ១៥០ លានដុង ដើម្បីកែប្រែផ្ទៃដី ទិញពូជមាន គុណភាពខ្ពស់ និងដំឡើងប្រព័ន្ធស្រោចទឹក។ ដោយអនុវត្តបច្ចេកទេសតាមលំដាប់ ចម្ការឈើហូបផ្លែលូតលាស់ល្អ។ ក្រោយរយៈកាល ៣ ឆ្នាំ ទម្រង់ចាប់ផ្តើមអំណោយផលស្ថិរភាព។ បច្ចុប្បន្ន គិតជាមធ្យមក្នុងមួយឆ្នាំ ក្រោយពេលទូទាត់ប្រាក់ចំណាយ គ្រួសាររបស់លោកមាណាំទទួលបានប្រាក់ចំណេញប្រមាណ ១០០ លានដុង។

មិនត្រឹមតែគិតគូរសេដ្ឋកិច្ចគ្រួសារ លោកមាណាំនៅទាំងចែករំលែកបទពិសោធន៍ក្នុងការផលិតជាមួយមាមីងខ្មែរ នៅក្នុងភូមិ តាំងពីការជ្រើសរើសពូជ ការប្រើជី រហូតដល់ ការពារកម្ចាត់ ជំងឺដង្កូវ។ ផ្តើមពីនោះ មានគ្រួសារជាច្រើនបានអនុវត្តតាមការផ្លាស់ប្តូរដំណាំឲ្យសមស្រប និងមានប្រភពចំណូលកើនឡើង។

លោកមាណាំឲ្យដឹង៖ ដោយសារបានរដ្ឋឧបត្ថម្ភទុន និងបានចូលរួមវគ្គហ្វឹកហាត់បច្ចេកទេសខ្ញុំមានលក្ខណៈវិនិយោគទម្រង់នេះ។ ឆ្នាំនេះ ខ្ញុំនឹងខិតខំសងបំណុលឲ្យអស់ បន្ទាប់មកពង្រីកផ្ទៃដី និងថែចម្ការឈើហូបផ្លែ ដើម្បីសេដ្ឋកិច្ចគ្រួសារកាន់តែរីកចម្រើនជាងមុន។

សមមិត្ត ថាច់មិញកាញ់ ប្រធានគណៈកម្មការប្រជាជនភូមិ ចុងទ័ព បានឲ្យដឹង៖ ទម្រង់របស់លោកមាណាំមិនត្រឹមតែផ្តល់ប្រភពចំណូលស្ថិរភាពសម្រាប់គ្រួសារប៉ុណ្ណោះទេ នៅទាំងសមស្របនឹងទិសដៅពង្រីកកសិកម្ម ស្ថិរភាព និងរួមចំណែកក្នុងការកសាងភូមិជនបទថ្មីខ្នាតគំរូទៀតផង។

គ្រួសាររបស់លោកមាណាំ បានទទួលកិត្តិនាមជា "កសិករផលិត-ធ្វើអាជីវកម្មពូកែ" ថ្នាក់ ឃុំនិងថ្នាក់ខេត្ត។ លោកមា ជាគំរូកសិករពូកែមួយរូបក្នុងចលនាកសិករខ្មែរ ឆ្លងកាត់ការលំបាក និងចេះប្រើប្រាស់គោលនយោបាយឧបត្ថម្ភ រួមចំណែកកសាងភូមិចុងទ័ពឲ្យកាន់តែរីកចម្រើន៕

អត្ថបទ-រូបថត៖ **សុខា**



កសិករឡឹម រ៉ាំងណាំ ថែទាំចម្ការ ក្រូចថ្លុង។

## ជូនអំណោយចំនួន ៥៣០ ចំណែកដល់គ្រួសារក្រីក្រ លំបាក និងសិស្សានុសិស្ស



*ព្រះតេជព្រះគុណ ថាច់សុវណ្ណ (ទី២ ខាងស្ដាំ) រួមជាមួយព្រះឧបជ្ឈាយ៍ ព្រះតេជគុណ ព្រមទាំងតំណាងសប្បុរសជនជូនអំណោយដល់ប្អូនៗ។*

**កាល**ពីថ្ងៃទី ៣០ ខែសីហា ព្រះតេជព្រះគុណ ថាច់សុវណ្ណ ព្រះចៅអធិការវត្តផ្ទោរអំពូង ឃុំឡុងហ៊ីប និងសប្បុរសជននៅទីក្រុងហូជីមិញ សហការជាមួយរដ្ឋអំណាចមូលដ្ឋាន ចាត់តាំងជូនអំណោយ ៥៣០ ចំណែកដល់គ្រួសារក្រីក្រ គ្រួសារលំបាក និងសិស្សានុសិស្ស។

អំណោយដែលបានជូនដល់គ្រួសារក្រីក្ររួមមាន អង្ករ មីព្រមទាំងរបស់ប្រើប្រាស់មួយចំនួនទៀត រីឯអំណោយដែលជូនចំពោះសិស្សានុសិស្ស រួមមានសិក្ខូបករណ៍ចាំបាច់មួយចំនួន គិតជាតម្លៃក្នុងមួយចំណែៗ ចំនួន ៣០០.០០០ ដុង។ អំណោយអាស្រ័យព្រះតេជគុណ ថាច់សុវណ្ណ បំផុសចលនាអ្នកស្រី ង្វៀងធីបែ និងអ្នកស្រី ហ៊ុញង៉ុកទ្រិញ នៅទីក្រុងហូជីមិញឧបត្ថម្ភ។ អំណោយសំដៅរួមចំណែកជាមួយរដ្ឋអំណាចមូលដ្ឋាន គិតគូរបាល្អ ចំពោះ គ្រួសារក្រីក្រ លំបាកនាឱកាសអំណរអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា។ ចំពោះប្អូនៗ សិស្សានុសិស្សវិញ មានសិក្ខូបករណ៍បានគ្រប់គ្រាន់ដើម្បីត្រៀមបម្រុងឈានចូលឆ្នាំសិក្សាថ្មី ២០២៥- ២០២៦។

បានដឹងថា ក្រៅពីជូនអំណោយខាងលើ ក្នុងថ្ងៃដដែលដែរ ព្រះតេជព្រះគុណ ថាច់សុវណ្ណ នៅទាំងសហការជាមួយរដ្ឋអំណាចមូលដ្ឋានធ្វើពិធីលែងពូជផលផលលជាច្រើនពាន់ក្បាលទៅក្នុងបរិស្ថានធម្មជាតិដើម្បីសម្ដែងពីការដោះលែងអាយុជីវិតសត្វ បង្កប្រភពផលផលនៅក្នុងបរិស្ថានធម្មជាតិ៕

ដំណឹង-រូបថត៖ **សម្បត្តិ**

## ត្រៀមចាត់តាំងទិវាវប្បធម៌យុវជនខ្មែរអំណរបុណ្យសែនដូនតាឆ្នាំ២០២៥

**នៅ**ថ្ងៃទី ២២ ខែកញ្ញាខាងមុខ សម្ព័ន្ធយុវជនខេត្តនឹងចាត់តាំងទិវាវប្បធម៌យុវជនជនជាតិខ្មែរ នៅវត្តជ្រោយទន្សា ឃុំហាមយ៉ាង ខេត្តវិញឡុង ដើម្បីអំណរបុណ្យសែនដូនតាឆ្នាំ ២០២៥ ដោយមានតំណាង ១៦០ នាក់ចូលរួម។

លោក ង្វៀងថាញ់ញ៉ា អនុលេខាសម្ព័ន្ធយុវជនខេត្ត បានឲ្យដឹង៖ អនុវត្ត ផែនការលេខ ១២-KH/TĐTN-PT ចុះថ្ងៃទី ៦ ខែសីហា ឆ្នាំ ២០២៥ របស់គណៈប្រតិបត្តិការសម្ព័ន្ធយុវជនខេត្តវិញឡុង ស្ដីពីផែនការចាត់តាំងទិវា វប្បធម៌យុវជនខ្មែរដើម្បីអំណរបុណ្យសែនដូនតា ឆ្នាំ ២០២៥ មកទល់ពេលនេះ សម្ព័ន្ធយុវជនខេត្តបានសហការជាមួយសម្ព័ន្ធយុវជនមូលដ្ឋានស្ថិតក្រោមឱវាទត្រៀមបណ្ដាផ្នែកដើម្បីចាត់តាំងទិវានេះ។ក្នុងពិធីបុណ្យនេះមាន ត្រៀមចេញបង្ហាញមុខក្លឹបយុវជនចូលរួមអភិរក្ស និងផ្សព្វផ្សាយអត្តសញ្ញាណវប្បធម៌ជនជាតិខ្មែរ ព្រមទាំងចាត់តាំងសកម្មភាពជាច្រើនមាន កម្មវិធីផ្ដោះប្ដូរវប្បធម៌សិល្បៈ កីឡា និងល្បែងប្រជាប្រិយជាដើម។ ទិវាវប្បធម៌យុវជនខ្មែរចាត់តាំងឡើងដើម្បីអំណរបុណ្យសែនដូនតា បង្កបរិយាកាសជូនយុវកុមារ ជាពិសេសយុវកុមារជនជាតិខ្មែរបានលេងកម្សាន្តមានប្រយោជន៍ ។ ឆ្លងតាមរយៈនោះ ដើម្បីរួមចំណែកក្នុងការអភិរក្សតម្លៃវប្បធម៌ប្រពៃណី ជំរុញស្មារតីសាមគ្គី និងមោទនៈ ក្នុងចំណោមយុវជនខ្មែរ ព្រមទាំងពង្រឹងអង្គការចាត់តាំងសម្ព័ន្ធយុវជន និងសមាគមយុវជននៅមូលដ្ឋានឲ្យកាន់តែរឹងមាំ៕

**សុជា**

## រក្សាបានល្អរបៀបរស់នៅអារ្យធម៌ក្នុងពិធីអាពាហ៍ពិពាហ៍ បុណ្យសព

*សារាចរលេខ ០៥/CT-TTg ចុះថ្ងៃទី ០៩/២/២០១៨ របស់នាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាល "ស្ដីពីជំរុញមាំអនុវត្តរបៀបរស់នៅអារ្យធម៌ក្នុងពិធីអាពាហ៍ពិពាហ៍ បុណ្យសព" បានចេញផ្សាយ និងកាន់តែស៊ីជម្រៅទៅក្នុងទឹកចិត្តប្រជាជន បានក្លាយជាគោលមាគ៌ាថ្មី ជួយឱ្យជនរួមជាតិខ្មែរកែកុនមកវិញលក្ខណៈប្រជុំជីវភាព ពង្រីកល្អប្រពៃណីត្រចះត្រចង់ បំបាត់ទំនៀមចាស់គំរិល សម្ដែងងច្បាស់ពីរបៀបរស់នៅថ្មីក្នុងសម័យកាលអារ្យធម៌ ទំនើប។*

**នៅ**ឃុំង៉ូវឡាក ជាមូលដ្ឋានដែលមានជនរួមជាតិខ្មែររស់នៅច្រើន។ ឃុំបានបង្កើតឡើងលើមូលដ្ឋានឯកូបនីយកម្មឃុំង៉ូវឡាក និងឃុំថាញ់ហ្វាស៊ើង។ ក្រោយពេលឯកូបនីយកម្ម ឃុំមានភូមិចំនួន ១៦ មានគ្រួសារប្រជាជនចំនួន ៧.១៨៣ គ្រួ ដោយមានចំនួនមនុស្សរាយ ៣២.៣០៩ នាក់ ក្នុងនោះជនរួមជាតិខ្មែរមានអត្រា ៦៥,០៥%នៃចំនួនប្រជាជនរួម។ ដោយអាស្រ័យអនុវត្តការងារផ្សព្វផ្សាយបានល្អរបស់រដ្ឋអំណាចមូលដ្ឋានពីខ្លឹមសារនៃសារាចរលេខ ០៥ ម៉្លោះហើយស្មារតីយល់ដឹងរបស់ប្រជាជននិយាយរួម ជនរួមជាតិខ្មែរនិយាយដោយឡែកកាន់តែបានលើកកម្ពស់ ជនរួមជាតិខ្មែរអនុវត្តល្អរបៀបរស់នៅអារ្យធម៌ក្នុងពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យសព។



*ទំនៀមអាពាហ៍ពិពាហ៍តាមបែបសម័យទំនើបរបស់គូបុរស-ស្ត្រីជនជាតិខ្មែរ។*

រយៈពេលកន្លង បានរដ្ឋឧបត្ថម្ភកសាងផ្ទសផុលឈាបនដ្ឋាននៅតាមបណ្ដាវត្តលើភូមិសាស្ត្រ ក៏ជាការរួមចំណែកឱ្យជនរួមជាតិខ្មែរអនុវត្តល្អបែបបទអារ្យធម៌ក្នុងពិធីបុណ្យសពផងដែរ។ ជាក់ស្ដែងគឺបន្ថយបានការឥទ្ធិពលដល់បរិស្ថានពេលមានសពយកទៅបូជា។ លោក ថាច់ជឹក អ្នកមានប្រជាប្រិយភាពក្នុងជនរួមជាតិខ្មែរ នៅភូមិដើមជ្រៃ ឃុំង៉ូវឡាក បានឱ្យដឹងថា៖ ជាប្រជាជននៅមូលដ្ឋាន ឃុំ កត់សម្គាល់ឃើញថា ជនរួមជាតិខ្មែរអនុវត្តល្អពីរបៀបរស់នៅអារ្យធម៌ក្នុងពិធីអាពាហ៍ពិពាហ៍ ក្នុងពិធីបុណ្យសព ឬពិធីបុណ្យផ្សេងទៀត ជាការសម្ដែងពីភាពជឿនលឿនថ្មីក្នុងជីវភាព។ រាល់ពិធីអាពាហ៍ពិពាហ៍មិនចាត់តាំងដោយរបៀបគគ្រឹកគគ្រេង ខ្ជះខ្ជាយសម្ភារពេលវេលា។

លោក ថាច់ជឹកចែករំលែកបន្ថែមទៀតថា៖ កាលពីមុន មាមីងខ្មែរមួយចំនួន ពេលដែលជួបប្រទះរឿងរ៉ាវអ្វីម្យ៉ាងជាយថាហេតុ ច្រើនរកគ្រូទស្សន៍ទាយពីជតាភសី ខ្លាចក្រែងមានអារក្ស អ្នកតាបៀតបៀន មិនសូវចាប់អារម្មណ៍ដល់កត្តាឥទ្ធពលផ្សេងៗ ជាក់ស្ដែងដូចជាមានមនុស្សក្នុងគ្រួសារឈឺថ្កាត់ សត្វចិញ្ចឹមក្នុងគ្រួសារត្រូវងាប់ ច្រើនសម្គាល់ថាខុសលើអារក្សនេះ អារក្សនោះ មិនមានការចាប់អារម្មណ៍ដល់កត្តាបង្កជាជំងឺ។ បច្ចុប្បន្នវិទ្យាសាស្ត្រកាន់តែជឿនលឿន ជនរួមជាតិខ្មែរក៏បែរមកជាមួយរបៀបរស់នៅទំនើប រាល់ពេលដែលមានអ្នកឈឺថ្កាត់ក៏នាំទៅពិនិត្យព្យាបាលនៅមន្ទីរពេទ្យ ឬមូលដ្ឋានដែលជំនាញពិនិត្យ ព្យាបាលជំងឺ។ សត្វចិញ្ចឹមឈឺទៅរកពេទ្យសត្វ ផ្ដើមពីនោះគាត់បន្ថយបានពីការអន្តរាយធំដុំ។

ព្រះតេជព្រះគុណ ថាច់សេដ្ឋា ព្រះពហុស្សូត វត្តធំ មានថេរដីកាថា៖ អនុវត្តរបៀបរស់នៅអារ្យធម៌ កាន់តែជួយឱ្យជនរួមជាតិខ្មែរបង្កើនការប្រតិបត្តិល្អពីគោលការណ៍ គោលមាគ៌ារបស់បក្ស គោលនយោបាយ ច្បាប់របស់រដ្ឋ បំបាត់ចោលបណ្ដាអបាយមុខសង្គម។

អនុវត្តល្អរបៀបរស់នៅអារ្យធម៌ក្នុងពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យសព ក៏បានជនរួមជាតិខ្មែរកំណត់ថាគប្បីអនុវត្តឱ្យបានគ្រប់គ្រាន់សំណុំបែបបទតិតយុត្តិមួយចំនួន៖ គូបុរសស្ត្រី មុនពេលចាត់តាំងពិធីអាពាហ៍ពិពាហ៍គឺត្រូវចុះឈ្មោះនៅគណៈកម្មាធិការប្រជាជនឃុំដើម្បីទទួលបានការផ្ដល់ជូនលិខិតបញ្ជាក់អាពាហ៍ពិពាហ៍ អ្នកស្លាប់បាត់បង់ជីវិតនោះក៏មានតំណាងក្នុងគ្រួសារទៅកាន់គណៈកម្មាធិការប្រជាជនឃុំដើម្បីចុះឈ្មោះជម្រាបពីការស្លាប់ត្រូវតាមច្បាប់ដែលបានកំណត់។

បងស្រី ថាច់ធីមន្ថា នៅភូមិខ្នាចទទឹង ឃុំង៉ូវឡាក បានឱ្យដឹងថា៖ កូនប្រុសរបស់ខ្ញុំទៅធ្វើការស៊ីឈ្នួលនៅឯក្រុមហ៊ុនមួយក្នុងខេត្តដុងណាយក្នុងរយៈពេលជាច្រើនឆ្នាំ ក្រោយពេលស្ម័គ្រចិត្តរៀបការជាមួយកូនក្រមុំរបស់អ្នកនៅខេត្តតីនិញ ខ្ញុំតឿនឱ្យកូនទាំងពីរមកចុះឈ្មោះអាពាហ៍ពិពាហ៍នៅគណៈកម្មាធិការប្រជាជនឃុំ។ ស្ដាប់តាមបណ្ដាំម៉ែ កូនរបស់ខ្ញុំបានឆ្លៀតពេលមកផ្ទះដើម្បីបំពេញបណ្ដាសំណុំបែបបទទាក់ទងដល់អាពាហ៍ពិពាហ៍។ ខ្ញុំគិតឃើញថា មុនពេលរៀបអាពាហ៍ពិពាហ៍រួមរស់ជាប្ដីប្រពន្ធ ត្រូវអនុវត្តបណ្ដាជំហានតាមការកំណត់របស់ច្បាប់ឱ្យបានគ្រប់សព្វ នៅថ្ងៃមុខប្រសិនបើជ្រុលជ្រួសមានរឿងអ្វីងាយដោះស្រាយ។

ចំពោះអ្នកដែលស្លាប់ ត្រូវចុះឈ្មោះជម្រាបការស្លាប់ ពីព្រោះមានប្រការជាច្រើនទាក់ទងដល់ទ្រព្យសម្បត្តិ កូនៗដែលជាអ្នកស្នងមរតក មានអ្នកខ្លះស្ថិតក្នុងវ័យចាស់កំពុងទទួលបានឧបភោគសោធនប្រចាំខែពីរដ្ឋ ហើយស្រាប់តែបាត់បង់ជីវិតនោះ ការជម្រាបពីការស្លាប់ជាការសែនចាំបាច់ ពីព្រោះត្រូវដោះស្រាយទទួលខ្ទង់របបឧបភោគសោធនចុងក្រោយបង្អស់មួយលើកដើម្បីអ្នកចិញ្ចឹម ឬអ្នកមានបន្ទុកពាក់ព័ន្ធបានទទួល។

តាមប្រសាសន៍របស់លោក ង្វៀងវ៉ាំងយើយ ប្រធានគណៈកម្មាធិការប្រជាជនឃុំង៉ូវឡាក៖ សារាចរលេខ ០៥ "ស្ដីពីជំរុញមាំការអនុវត្តន៍របៀបរស់នៅអារ្យធម៌ក្នុងពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យសព" បានប្រជាជនទាំងមូលទទួលយក។ ក្នុងនោះមានពិធីកិច្ចមួយចំនួនបានជនរួមជាតិខ្មែរធ្វើការកែប្រែ ប៉ុន្តែនៅតែរក្សាបានអត្តសញ្ញាណវប្បធម៌ដោយឡែករបស់ជនជាតិ សំដៅកាត់បន្ថយការខ្ជះខ្ជាយ ជៀសវាងបានស្ថានភាពឆ្លៀតយកពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យដើម្បីប្រព្រឹត្តអំពើមិនល្អដូចជា ស្រាបាយ ល្បែងភ្នាល់ជាដើម៕

អត្ថបទ-រូបថត៖ **សម្បត្តិ**

# មន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញប្រកាសផ្សព្វផ្សាយ "ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច"




*តំណាងអនុវត្តពិធីប្រកាសផ្សាយប្រព័ន្ធ "ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច" នៅមន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញ។ រូបថត៖* ***ទ៉ុគសួខ***

**កាល**ពីថ្ងៃទី ២៨ ខែសីហាមន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញចាត់តាំងពិធីប្រកាសផ្សព្វផ្សាយសំណុំលិខិត "ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច"។

សំណុំលិខិត "ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច" (EMR) បានមន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញអនុវត្តចាប់តាំងពីខែវិច្ឆិកា ឆ្នាំ ២០២៤ (ទិញម៉ាស៊ីន បច្ចេកទេស ហ្វឹកហាត់បុគ្គលិករៀនសូត្របទពិសោធន៍។ល។)។

"ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច" នាំមកផលប្រយោជន៍ជាក់ស្តែងច្រើនដូចជា៖ ប្រព័ន្ធធ្វើតេស្ត ស្ទង់ជំងឺឆ្លងតាមរយៈរូបភាព អគារឱសថ និងក្រាំងព័ត៌មានគាំពារសុខាភិបាល អាចជួយវេជ្ជបណ្ឌិតពិនិត្យឆាប់រហ័ស កាត់បន្ថយពេលវេលារង់ចាំ សំណុំលិខិតរដ្ឋបាលងាយស្រួល។

ទិន្នន័យកំណត់ត្រាវេជ្ជសាស្ត្របានរក្សាទុកដោយសុវត្ថិភាព ធានាសម្ងាត់ រកបានដោយងាយស្រួល ទូទាត់គាំពារស្មោះត្រង់ ឧបត្ថម្ភការស្ថិតិមានប្រសិទ្ធភាព គ្រប់គ្រង ស្រាវជ្រាវវិទ្យាសាស្ត្រ កាត់បន្ថយប្រាក់ចំណាយផ្តិតសំណុំលិខិត និងជួយបុគ្គលិកសុខាភិបាលមានពេលដើម្បីថែទាំអ្នកជំងឺ។

វេជ្ជបណ្ឌិតហ្វិញហ៊ីវញ៉ឹង នាយកមន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញបានឲ្យដឹងថា៖ អនុវត្តសំណុំលិខិត "ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច" ជាជំហានជឿនលឿនសំខាន់ក្នុងការអនុវត្តន៍ឌីជីថលរបស់មន្ទីរពេទ្យ នាំយកបច្ចេកវិទ្យាមកបម្រើមនុស្ស កំណត់ទិសដៅដល់ការកសាងមន្ទីរពេទ្យប្រាជ្ញា លើកកម្ពស់គុណភាពការងារថែទាំសុខភាពប្រជាជន។

មានប្រសាសន៍នៅក្នុងពិធីប្រកាសផ្សព្វផ្សាយ "ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច" នេះ បណ្ឌិត វេជ្ជបណ្ឌិត ហូធីធូហាំង នាយិកាមន្ទីរសុខាភិបាលអះអាងថា៖ សំណុំ"ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច" ជាជំហានជឿនលឿនមួយសំខាន់ក្នុងដំណាក់កាលអនុវត្តឌីជីថលក្នុងផ្នែកសុខាភិបាល មានអត្ថន័យប្រដោយភាពទម្លុះទម្លាយក្នុងការផ្លាស់ថ្មីការងារគ្រប់គ្រង និងលើកកម្ពស់គុណភាពពិនិត្យ ព្យាបាលជំងឺ។ ការផ្សព្វផ្សាយឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិចមិនត្រឹមតែដើម្បីកាត់បន្ថយសំណុំលិខិត លើកកម្ពស់ការងារគ្រប់គ្រងព័ត៌មានសុខាភិបាល នៅទាំងជាទិសដៅឈានដល់ប្រព័ន្ធសុខាភិបាលប្រាជ្ញា ទំនើប សុវត្ថិភាព យកអ្នកជំងឺធ្វើជាមជ្ឈមណ្ឌល។

គិតដល់ថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០២៥ ខេត្តវិញឡុងមានមូលដ្ឋានសុខាភិបាលរដ្ឋបង្កើតចំនួន ១៦/៤៦ កន្លែងបានប្រកាសផ្សាយប្រព័ន្ធសំណុំលិខិត"ឯកសារវេជ្ជសាស្ត្រអេឡិចត្រូនិច" នេះជាជំហានដំបូងដើម្បីសន្សឹមៗឈានដល់ទម្រង់មន្ទីរពេទ្យប្រាជ្ញា៕

ប្រែសម្រួល៖ **តឺខឌ៉ុក**

# មន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញ៖ ផ្សព្វផ្សាយការពិនិត្យជំងឺតាមតម្រូវការ




*បើកសេវាកម្មពិនិត្យ ព្យាបាលជំងឺតាមតម្រូវការ។ រូបថត៖* ***ធីភឿខ***

**ម**ន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញ ទើបផ្សព្វផ្សាយបើកវគ្គពិនិត្យជំងឺតាមតម្រូវការ ស្ថិតក្រោមឱវាទផ្នែកពិនិត្យ និងព្យាបាលជំងឺតាមតម្រូវការ។ វគ្គពិនិត្យនិងព្យាបាលជំងឺតាមតម្រូវការ មាន ២ កន្លែង៖ កន្លែងពិនិត្យជំងឺតាមតម្រូវការបានដាក់នៅជាន់ខាងក្រោម មណ្ឌល D និងកន្លែងស្នាក់នៅព្យាបាលជំងឺបានដាក់នៅដោយឡែកនៅជាន់ទី ៩ មណ្ឌល E ដោយមាន ២២ បន្ទប់ និង ៥០ គ្រែពេទ្យ។

វគ្គពិនិត្យនិងព្យាបាលជំងឺតាមតម្រូវការទទួលនិងថែទាំបណ្តាអ្នកជំងឺស្ថិតក្រោមឱវាទផ្នែកជំនាញ ដូចជា៖ ជំងឺសរសៃឈាមបេះដូង ផ្លូវដកដង្ហើម ផ្លូវរំលាយអាហារ ខាងក្នុងសរីរកាយ សរសៃប្រសាទ សន្លាក់ឆ្អឹង លោហិតសាស្ត្រ តម្រងនោមស្ថិតក្រោមឱវាទនៃការថែទាំគ្រប់ថ្នាក់ដែលមានតម្រូវការព្យាបាលនិងថែទាំគុណភាពខ្ពស់។

ក្រៅពីនោះ ផ្នែកក៏ទទួល ព្យាបាលជំងឺតាមស្មារតីសហការជាមួយបណ្តាផ្នែកជំនាញថែទាំ ព្យាបាលខាងក្នុងមុន និងក្រោយពេលវះព្យាបាលជូនបណ្តាអ្នកជំងឺភ្នែក ធ្មេញ ថ្គាមមុខ ត្រចៀក ច្រមុះ បំពង់ក ជំងឺខាងក្រៅសរីរកាយ។ ទទួល វះកាត់ព្យាបាលសន្លាក់ឆ្អឹងខួរក្បាល និងសន្លាក់ឆ្អឹងខ្នង ផ្លូវរំលាយអាហារ ជំងឺសាច់ដុំ។

ទន្ទឹមនឹងនោះ ព្យាបាលជំងឺតាមតម្រូវការបានអនុវត្តបច្ចេកទេសឯកទេសជាច្រើនដោយមានប្រព័ន្ធឧបករណ៍សុខាភិបាលទំនើបដូចជា៖ ធ្វើកោសល្យវិច័យ doppler ពណ៌ Citi Scan 128 និងម៉ាស៊ីនកាត់ ២៥៦ CTស្ទង់ជំងឺ MRI ម៉ាស៊ីនឆ្លុះឯកផ្លូវរំលាយអាហារ ត្រចៀក ច្រមុះ បំពង់ក វាស់កម្រិតទន់ជ្រាយរបស់ឆ្អឹង បំបែកក្រួសក្នុងតម្រងនោម ប្រព័ន្ធរ៉ូបូតស្តារឡើងវិញសរីរាងកាយ ម៉ាស៊ីនដុតដុំពកក្នុងថ្លើម ពកសាច់ដុំបំពង់សំឡេង។ល។ ជួយព្យាបាលជូនអ្នកជំងឺឲ្យឆាប់ជាសះស្បើយ។

វេជ្ជបណ្ឌិតហ្វិញហ៊ីវញ៉ឹង នាយកមន្ទីរពេទ្យព្យាបាលពេទ្យត្រាវិញឲ្យដឹងថា៖ "ផ្នែកពិនិត្យ និងព្យាបាលជំងឺតាមតម្រូវការដំណើការសកម្មភាពមានសារសំខាន់ កត់សម្គាល់ជំហានជឿនលឿនថ្មីក្នុងការងារការពារ និងថែទាំសុខភាពជូនប្រជាជន។ ការពង្រីកសេវាកម្មពិនិត្យ ព្យាបាលជំងឺតាមតម្រូវការជាទិសដៅចាំបាច់ផង និងឆ្លើយតបតម្រូវការឧបករណ៍ពីមួយថ្ងៃទៅមួយថ្ងៃកាន់តែកើនឡើងរបស់ប្រជាជន ជាពិសេសគឺបណ្តាអ្នកជំងឺដែលមានលក្ខណៈសេដ្ឋកិច្ច និងតម្រូវការបានថែទាំ ព្យាបាល និងបម្រើក្រៅពីបណ្តាសេវាកម្មសាធារណៈកំពុងបានអនុវត្តនៅនឹងមន្ទីរពេទ្យ"៕

ប្រែសម្រួល៖ **តឺខឌ៉ុក**

# បរិយាកាសអំណរបុណ្យឯករាជ្យ...

*(តមកពីទំព័រទី២)*

សារលិខិតលេខ ១៧១២៩-CV/VPTW ចុះថ្ងៃទី ២៨/៨/២០២៥ របស់ការិយាល័យមជ្ឈិមបក្ស ការិយាល័យនយោបាយ បានឯកភាពគោលការណ៍ជូនអំណោយដល់ប្រជាជននាឱកាសអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា" ក្នុងប្រជាជនម្នាក់ៗទទួលបានអំណោយ ១០០ ពាន់ដុងដើម្បីអំណរបុណ្យឯករាជ្យជាតិ។

អនុវត្តសារទូរលេខខាងលើ បណ្តាមូលដ្ឋានក្នុងខេត្ត ក៏ប្រញាប់ប្រញាលអនុវត្តដោះស្រាយជូនអំណោយតាមចំនួនដែលបានកំណត់ដល់ប្រជាជន។

នៅកន្លែងដោះស្រាយជូនអំណោយដល់ប្រជាជនស្ថិតនៅភូមិរកាលិច ឃុំញ៉ីទ្រៀង គិតដល់ពេលប្រមាណម៉ោង ១៦ នៃថ្ងៃទី ០១ ខែកញ្ញា ដោះស្រាយសម្រេចជាង ៩៦% នៃចំនួនប្រជាជនមកទទួលអំណោយ។ តាមប្រសាសន៍របស់អ្នកស្រី ត្រៀងធីយ៉ឹមថ សមាជិកាក្រុមផ្តល់ជូនអំណោយដល់ប្រជាជន៖ រយៈពេលដំបូង ការដោះស្រាយអំណោយរបស់ក្រុមជួបការលំបាកមួយចំនួន អាស្រ័យប្រព័ន្ធទិន្នន័យដំណើរការមិនបានរលូន។ គិតដល់ពេលប្រមាណម៉ោង ១៥ នៃថ្ងៃដដែល ការដោះស្រាយជូនប្រជាជនសម្រេចជាង ៩០% នៃចំនួនអ្នកមកទទួល នៅតែករណីមួយចំនួនមិនបញ្ជាក់បានពីលិខិតពាក់ព័ន្ធផ្ទាល់ខ្លួនទើបមិនអាចដោះស្រាយបាន។ ឃុំបន្តប្រកាសដល់ប្រជាជនមកទទួលប្រាក់ និងនាំមកជាមួយនូវលិខិតផ្ទាល់ខ្លួនតំណាងឱ្យសមាជិកក្នុងគ្រួសារ ដើម្បីដោះស្រាយឱ្យសម្រេចក្នុងថ្ងៃនោះតែម្តង ធានាចំនួនប្រាក់បានទៅដល់ប្រជាជនមុនថ្ងៃ ២ ខែកញ្ញា។

កន្លែងដោះស្រាយប្រាក់អំណោយជូនប្រជាជននៅភូមិរកាលិច រួមមានប្រជាជនបណ្តាភូមិមកទទួលគឺ៖ រកាកើត រកាលិច និងភូមិទ្រព្រះបាទ ដោយមានចំនួនប្រជាជនជិត ៤.០០០ នាក់ ក្នុងនោះមានអត្រាជនរួមជាតិខ្មែរជាង ៨២%។

បងស្រី សឺនធីក្រាញ់ នៅភូមិទ្រព្រះបាទ សំណេះសំណាលថា៖ ពេលឮដំណឹងថាមានអំណោយរបស់រដ្ឋក្នុងឱកាសអំណរបុណ្យជាតិ ខ្ញុំមកទីនេះយ៉ាងរួតរះ។ ដល់ពេលប្រមាណម៉ោង ១០ និង ៣០ នាទី គ្រួសារខ្ញុំបានដោះស្រាយដោយមានសមាជិកចំនួន ៥ នាក់។ អំណរបុណ្យជាតិឆ្នាំនេះ កូនៗទាំង ៣ នាក់របស់ខ្ញុំដែលទៅរកស៊ីនៅខេត្តផ្សេងក៏បានវិលត្រឡប់មកផ្ទះ មានទឹកប្រាក់នេះគ្រួសារខ្ញុំនឹងចាត់តាំងពេលបាយជួបជុំគ្នាអំណរបុណ្យជាតិឱ្យបានប្លែកបន្តិច។ ខ្ញុំយល់ឃើញថា អំណោយមានតម្លៃមិនជាច្រើនប៉ុន្មានឡើយ ប៉ុន្តែមានអត្ថន័យធំធេង សម្តែងពីការយកចិត្តទុកដាក់របស់បក្ស និងរដ្ឋដល់ទូទាំងប្រជាជន។

រីករាយជាមួយបរិយាកាសអំណរអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា ដល់ថ្ងៃទី ២ ខែកញ្ញា ប្រជាជននៅទាំងបានតាមដានទូរទស្សន៍ជាតិ (VTV1) ផ្សាយបន្តផ្ទាល់ពីពិធីយោធាយាត្រា ព្យុហយាត្រាប្រកបដោយទិដ្ឋភាពយ៉ាងជក់ចិត្ត បង្កជាបរិយាកាសរីករាយ មានអារម្មណ៍យ៉ាងរំភើប ពេលបានរស់នៅក្នុងប្រទេសសន្តិភាពរុងរឿង៕

អត្ថបទ-រូបថត៖ **សម្បត្តិ**

# ពិធីព្យុហយាត្រាអំណរអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា

អំណរអនុស្សាវរីយ៍ឆ្នាំទី ៨០ ទិវាបដិវត្តន៍ខែសីហា និងបុណ្យជាតិ ២ កញ្ញា បានចាត់តាំងនៅនឹងទីធ្លាបាឌិញ ទីក្រុងហាណូយនាព្រឹកថ្ងៃទី ២ ខែកញ្ញា។ បន្ទាប់ពិធីបុណ្យរបស់ថ្នាក់រដ្ឋ ពិធីព្យុហយាត្រាអាស្រ័យដោយក្រសួងការពារជាតិសហប្រតិបត្តិការជាមួយក្រសួងនគរបាល ក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ទីក្រុងហាណូយ និងបណ្ដាគណៈ ក្រសួង ផ្នែក ស្ថាប័ន អង្គភាពពាក់ព័ន្ធចាត់តាំងអនុវត្ត ដោយមាន ០៦ អង្គភាពកងកម្លាំងចូលរួមជាមួយទ្រង់ទ្រាយមនុស្សជាង ៣០.០០០ នាក់។

ក្នុងនោះ មានផែនរដ្ឋសភា ៤ ផែន តំណាងកងកម្លាំងប្រដាប់អាវុធប្រជាជន បណ្ដាផែនកងទ័ពបរទេស (ចិន រុស្ស៊ី ឡាវ កម្ពុជា) កងកម្លាំងរថយន្ត កាំភ្លើងធំ រថយន្តយោធា រថយន្តពិសេសនគរបាល កងកម្លាំងព្យុហយាត្រានៅលើសមុទ្រចំនួន ៤៣ ផែន ក្បួនព្យុហយាត្រាមហាជន ១២ និង ផែនវប្បធម៌ កីឡា ១។



ផែនទង់ជ័យទ័ពអាស្រ័យឧត្ដមសេនីយ៍ឯកបម្រុង ង្វៀងហុងថាយ សមាជិកគណៈប្រតិបត្តិការមជ្ឈិមបក្ស អនុរដ្ឋមន្ត្រីក្រសួងការពារជាតិបញ្ជានាំមុខបណ្ដាផែនតំណាងឱ្យកងទ័ពប្រជាជនវៀតណាមវីរភាព និងកងសេនាជន។



បណ្ដាយុទ្ធនារីស្រស់ស្អាតរបស់ផែននាយទាហានយុទ្ធពេទ្យ។



ផែនកងទ័ពកម្ពុជា។



ផែនតម្រួតចល័តសេះ។



ផែននាយទាហានការពារព្រំដែន។



ផែននាយទាហានកងតម្រួតសមុទ្រវៀតណាម។



ផែនកងទ័ពចិន។



ផែនកងទ័ពរុស្ស៊ី។

**ស្វែងយល់វាក្យបរិវត្តន៍វៀតណាម-ខ្មែរ**

*(សិក្សា ស្រាវជ្រាវ និងប្តូរយោបល់)*

- Chủ lực = ទ័ពរៀបរយ ទ័ពស្រេច។
- Các văn bản hướng dẫn = បណ្ដាសារលិខិតណែនាំ។
- Các ban xây dựng đảng = បណ្ដាគណៈកម្មាធិការកសាងបក្ស។
- Công tác luân chuyển cán bộ = ការងារផ្ទេរជូនកម្មាភិបាល។
- Công tác quy hoạch đào tạo cán bộ = ការគ្រោងផែនការបណ្ដុះបណ្ដាលកម្មាភិបាល។
- Chậm nhân rộng = ការពង្រីកទូលំទូលាយនៅយឺតយ៉ាវ។
- Quy hoạch bố trí sử dụng cán bộ chưa đáp ứng yêu cầu = គ្រោងផែនការរៀបចំ ប្រើការកម្មាភិបាលមិនទាន់ឆ្លើយតបតម្រូវការ។

*ទីស្នាក់ការ ៥០ ផាមវ៉ាយបៀង សង្កាត់ភៀកហូវ ខេត្តវិញឡុង ទូរស័ព្ទ ០២៧០៣.៨២២៥៩១ Phongbkmtv@gmail.com លិខិតអនុញ្ញាតលេខ ១៩៨/GP-SVHTTDL អាស្រ័យមន្ទីរវប្បធម៌ កីឡានិងទេសចរណ៍ ថ្ងៃទី ២១/៨/២០២៥
អគ្គនិពន្ធនាយកកាសែត និងវិទ្យុ ទូរទស្សន៍វិញឡុង ឡេថាញ់ភឿង អគ្គនិពន្ធនាយករងកាសែត និងវិទ្យុ ទូរទស្សន៍វិញឡុងទទួលបន្ទុកភាសាខ្មែរ ស៊ឺនឃ៊ីម បោះពុម្ពរោងពុម្ព-ក្រុមហ៊ុនចំកាត់វប្បធម៌ចម្រុះត្រាវិញខេត្តវិញឡុង។